# ខ្លឹមសារសង្ខេប សាលក្រមរឿងក្តីប្រាសាទព្រះវិហារ

## Case concerning the Temple of Preah Vihear (Merit)

## Judgment of 15 June 1962

**ពាក្យគន្លឹះ** អធិបតេយ្យភាព, ការទទួលយកដោយស្ងៀមស្ងាត់ (Acquiescence) ការបាត់សិទ្ធិក្នុងការប្តឹងទាមទារ (estoppel)។

***សំណួរៈ*** តើការមិនតវ៉ា ឬទាមទារក្នុងពេលវេលាមួយ នាំឲ្យមានការចាត់ថា ជាការព្រមទទួលដោយស្ងៀមស្ងាត់ និងនាំឲ្យបាត់បង់នូវសិទ្ធិនៃការទាមទារដែរទេ?

១. កម្ពុជានៅក្រោមអាណានិគមរបស់បារាំងតាំងពីឆ្នាំ ១៨៦៣ ហើយកិច្ចការងារអន្តរជាតិត្រូវបានធ្វើឡើងដោយប្រទេសបារាំង ជំនួសឲ្យកម្ពុជា។ ឆ្នាំ ១៩០៤ បារាំង និងថៃបានធ្វើសន្ធិសញ្ញា ស្តីពីទំនាក់ទំនងគ្នា ដែលនិងជាមូលដ្ឋានកំណត់ដែនសីមាផងដែរ។ សន្ធិសញ្ញា ឆ្នាំ ១៩០៤ ចែងតម្រូវឲ្យបង្កើតគណៈកម្មការចម្រុះកំណត់ព្រំដែន។ ឆ្នាំ ១៩០៦ មានកិច្ចប្រជុំរួមគ្នារវាងភាគីទាំងពីរ ក្នុងគោលបំណងកំណត់ព្រំដែន។ ភាគីទាំងពីរក្រោយមក បានព្រមព្រៀងបង្កើតសន្ធិសញ្ញាព្រំដែនទូទៅ ក្នុងឆ្នាំ ១៩០៧។ នាពេលកសាងផែនទី ដោយសារគ្មានមធ្យោបាយគ្រប់គ្រាន់ ***ភាគីថៃ បានស្នើឲ្យបារាំងជួយគូស*** ព្រំដែន ហើយការងារនេះបានបញ្ចប់ក្នុងឆ្នាំ ១៩០៧ ដដែល ដោយអាជ្ញាធរបារាំង ដែលជាសមាជិកនៃគណៈកម្មការចម្រុះ។ ឆ្នាំ ១៩០៨ ផែនទី ដែលដាក់ប្រាសាទព្រះវិហារក្នុងអធិបតេយ្យកម្ពុជា ត្រូវបានបញ្ជូនទៅភាគីថៃ។

២. បន្ទាប់ក្រោយមក បញ្ហាព្រំដែន ចាប់ផ្តើមមានភាពកកើរកូស ដោយថៃអះអាងថា ប្រាសាទព្រះវិហារជារបស់ខ្លួន ហើយបានចូលកាន់កាប់ក្នុងឆ្នាំ ១៩៥៤ ដែលនាំឲ្យកម្ពុជា បានដាក់ពាក្យបណ្តឹងប្រឆាំងនឹង ថៃទៅតុលាការយុត្តិធម៌អន្តរជាតិ ក្នុងឆ្នាំ ១៩៥៩។ ថៃ បានអះអាងថាខ្លួនមិនទទួលស្គាល់សមត្ថកិច្ចរបស់តុលាការនេះ ហើយសូមឲ្យតុលាការបដិសេធបណ្តឹង។ ទោះបីជាយ៉ាងនេះក្តី តុលាការ

រកឃើញថា ខ្លួនមានសមត្ថកិច្ច និងបន្តពិនិត្យមើលអង្គសេចក្តី ថាតើមានការបំពានបូរណភាពដែនដី ដូចភាគីកម្ពុជា បានអះអាងដែរឬទេ?[1]

៣. ថៃព្យាយាមបដិសេធផែនទី។ វាមិនមែនជារបស់គណៈកម្មការចម្រុះ ហើយគណៈកម្មការនេះមិនបានទទួលស្គាល់ជាផ្លូវការទេ។ ដូចនេះ ផែនទី មិនចងជាកាតព្វកិច្ចទេ។ ក៏ប៉ុន្តែ តាមអង្គហេតុ ថៃជាអ្នកស្នើសុំឲ្យមន្ត្រីបារាំងជួយ ហើយមន្ត្រីទាំងនោះ ជាសមាជិកនៃគណៈកម្មការចម្រុះ។ ផែនទីនេះ ត្រូវបានប្រគល់ជូនដល់មន្ត្រី ដែលបានសំដែងអំណរគុណដល់គណៈកម្មការចម្រុះ។ មន្ត្រីទទួលផែនទី បានដឹងច្បាស់អំពីប្រាសាទព្រះវិហារ។ ក្នុងអំឡុងឆ្នាំ ១៩៣៤-១៩៣៥ ទោះបីជាថៃ បានជំទាស់ផែនទី ដូចនេះក្តី ក៏ថៃ នៅតែបន្ត បោះពុម្ព និងប្រើប្រាស់ផែនទី ដែលមានប្រាសាទព្រះវិហារក្នុងដែនដីកម្ពុជា(**ទំព័រ ទី២៥**)។ បន្ទាប់ក្រោយមក ក្នុងឆ្នាំ ១៩៥៨ នៅពេលចរចាជាមួយនឹងកម្ពុជា ភាគីថៃក៏មិនបានចោទសួរអំពីបញ្ហា ផែនទីនេះផងដែរ (**ទំព័រ ទី២៤**)។ ជាចុងក្រោយ ក្នុងអំឡុងពេល ស្តេចថៃ មកទស្សនកិច្ចនៅប្រាសាទព្រះវិហារ ដែលនៅកំពូល មានដោតទង់ជាតិបារាំង តំណាងឲ្យកម្ពុជា អាជ្ញាធរថៃក៏មិនបានតវ៉ាជំទាស់អ្វីដែរ(**ទំព័រ ទី២៨**)។

៤. តុលាការបានរកឃើញថា *ក្នុងរយៈពេលដ៏យូរ ថៃមិនបានធ្វើការតវ៉ា* ហើយផ្ទុយទៅវិញ *ធ្វើសកម្មភាពទាំងឡាយ ដែលហាក់មានសង្គតិភាពគ្នា បង្ហាញថា ប្រាសាទព្រះវិហារជារបស់កម្ពុជា។* មូលហេតុទាំងនេះ មិនត្រូវបានលប់ ដោយមូលហេតុថា វាជាទង្វើខុសឆ្គងនៃអាជ្ញាធរក្រោមរបស់ខ្លួនទទួលយកផែនទី និងមិនបានតវ៉ានេះទេ។ ផ្អែកលើមូលដ្ឋាននេះ តុលាការសម្រេចថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងអធិបតេយ្យភាពនៃកម្ពុជា និងទាមទារឲ្យថៃ បំពេញកាតព្វកិច្ចមួយចំនួន ដូចជា ដកទ័ពចេញពីប្រាសាទ ដែលខ្លួនចូលកាន់កាប់ដណ្តើម ក្នុងឆ្នាំ ១៩៥៤។

<u>**កំណត់សំគាល់**</u>៖ <u>ក</u>.មានមូលហេតុជាច្រើន ដែលនាំឲ្យកម្ពុជាឈ្នះក្តី តែអ្វីដែលគួរត្រូវកត់សំគាល់គឺទង្វើមិនតវ៉ាដ៏យូរ ដែលគេចាត់ថាបានព្រម ឬទទួលយក (acquiescence) ហើយដែល ធ្វើឲ្យភាគីបាត់សិទ្ធិក្នុងការប្តឹងទាមទារ (Estoppel)។ <u>ខ</u>.ក្នុងជីវិតឯកជន ទ្រឹស្តីនេះក៏ត្រូវបានអនុវត្តផងដែរ។ ក្នុងករណីគេមកធ្វើផ្ទះ លើដីស្របច្បាប់របស់យើង តែយើងមិនតវ៉ា ក្នុងវេលាយូរទៅ ភាគីនោះ គិតថាយើងអាច

[1] Case concerning the Temple of Preah Vihear (Preliminary Objections) Judgment of 26 May 1961.

បោះបង់ គេក៏ធ្វើកាន់តែធំឡើងៗ។ ក្រោយមក ពេលយើងប្តឹង តុលាការអាចនឹងបដិសេធ ថាយើងព្រមឲ្យគេដោយស្ងាត់ស្ងៀម និងលែងមានសិទ្ធិប្តឹង។ នេះវាបង្ហាញថា ដីរបស់យើង បានក្លាយជារបស់គេ។ ម្ចាស់ដី ចាញ់ក្តីឈឺចាប់ បន្ទោសតុលាការ ថាអយុត្តិធម៌ ស ទៅជាខ្មៅ។ តាមពិត តុលាការ សម្រេចតាមច្បាប់។ ដូចនេះ ជាបទពិសោធន៍ ពីសំណុំរឿងនេះ ប្រសិនករណី មានភាគីណាបំពាន យើងត្រូវតវ៉ា តវ៉ា ឬ ជំទាស់ឥតឈប់ (consistent objection) ក្នុងលក្ខណៈស៊ីសង្វាក់គ្នា (consistency)។ ប្រសិន បើមិនដូចនេះ ទេ គេថាយើងព្រម នឹងឈានទៅរកការបាត់បង់សិទ្ធិទាមទារ។ <u>គ.</u> នេះជាប្រយោជន៍នៃការដឹងច្បាប់ ដើម្បីការពារប្រយោជន៍ខ្លួន និង បង្ការកុំឲ្យគេបំពាន។ យើងមិនអាចអះអាងថា មិនបានដឹងច្បាប់ទេ (ការដោះសាររបៀបនេះ មិនទទួលយកទេ)។ តើធ្វើយ៉ាងដូចម្តេចទើបយើងដឹងច្បាប់? ដឹងច្បាប់តាមរយៈការផ្សព្វផ្សាយច្បាប់។ ដូចនេះ ច្បាប់ក្រោយពីចូលជាធរមានហើយ ត្រូវការផ្សព្វផ្សាយ ឬចុះក្នុងរាជកិច្ច។ ជាក់ស្តែង ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានទុករយៈពេលវេលា មួយ សម្រាប់ផ្សព្វផ្សាយ ដើម្បីឲ្យប្រជាពលរដ្ឋ និងអ្នកអនុវត្តបានដឹង។ ក្នុងន័យនេះ ការប្រកាសច្បាប់ប្រញាប់ (អនុវត្តភ្លាមក្រោយពីថ្ងៃចុះហត្ថលេខា) នាំឲ្យប្រជាពលរដ្ឋមិនអាចដឹងអំពីខ្លឹមសារនៃច្បាប់ជាមុន។ អាស្រ័យហេតុនេះ ជាទ្រឹស្តីច្បាប់ លុះត្រាតែមានភាពចាំបាច់បន្ទាន់ ទើប ច្បាប់ត្រូវបានប្រកាសឲ្យប្រើជាការប្រញាប់។ ក្នុងន័យនេះផងដែរ ដោយសារខ្លឹមសារច្បាប់មួយចំនួន ទាញចេញពីសាលក្រម ទើបក្នុងប្រព័ន្ធច្បាប់កុំមុនឡូ វាទាមទារឲ្យមានការបោះពុម្ពសាលក្រមជាទៀងទាត់ ដើម្បីធ្វើឲ្យសាធារណជន ឬអ្នកអនុវត្តច្បាប់បានដឹងពីខ្លឹមសារបច្ចុប្បន្នភាពនៃច្បាប់។ <u>ឃ.</u> ឆ្នាំ ២០១១ កម្ពុជា បានដាក់ពាក្យស្នើសុំ ឲ្យតុលាការដដែលបកស្រាយខ្លឹមសារសាលក្រម ឆ្នាំ ១៩៦២ ពាក់ព័ន្ធខ្លឹមសារនៃ ទំហំដីព័ទ្ធជុំវិញប្រាសាទព្រះវិហារ (Vicinity of Temple on Cambodian territory)។[2]

---

[2] Request for Interpretation of the judgment of 15 June 1962 in the case concerning the Temple Preah Vihear (Cambodia v. Thailand), judgment 11 November 2013.